N"05_Mar_A.qxd 06/16/2006 10:26 Morning Page 1

# ព្រាបសន្តិភាព ២០០៥

ផ្នែកអប់រំ
QPMW

ព្រឹត្តិបត្រព្រាបសន្តិភាព | អ្វីៗដើម្បីសន្តិភាព | ឆ្នាំទី២ លេខ ០៥ មេសា



មរណៈភាពរបស់ សម្តេចប៉ាប

មុងតេងញ៉ាត បួននាក់ កើតនៅស្រុកខ្មែរ



*ព្រាបសន្តិភាពសង្ខេបខ្លីពីព័ត៌មានជនជាតិភាគតិចតំបន់ភ្នំវៀតណាម*

បទសំភាសន៍



"មិនជាការងាយស្រួលទេដោយប្រើជើងក្នុងការសរសេរ " ទំព័រ២



សិក្ខាសាលាគ្រូ JS ទំព័រ២

មាតិកា


-រឿងហិប...............៣
- របៀបប្រើសាប៊ូ......៣
-កំណាព្យគុណម្តាយ. ៣
-អភិបូជាសម្តេចប៉ាប...៤


## ទន់ ចាន់ណារ៉េត " ខ្ញុំមានអារម្មណ៍ សោកសៅបំផុតចំពោះមរណភាពរបស់ម្តេចប៉ាប យ៉ូហាន ប៉ូលទី២"

*បទសំភាសន៍ជាមួយទូតជនពិការអន្តរជាតិ*

លោក **ទន់ ចាន់ណារ៉េត** អាយុ៤៥ឆ្នាំជាជនជាតិខ្មែរ លោកជាជនពិការម្នាក់ដែលមានតួនាទីជាទូតជនពិការអន្តរជាតិលុបបំបាត់គ្រាប់មីន (JS)។ ចាប់តាំងពីឆ្នាំ ១៩៩៤មកលោកមានសកម្មភាពជាច្រើនក្នុងការផ្សព្វផ្សាយអំពីការលុបបំបាត់គ្រាប់មីនក្នុងស្រុកនិងលើឆាកអន្តរជាតិ។ ឆ្នាំ១៩៩៥ក្នុងនាមលោកជាតំណាងអោយជនពិការរងគ្រោះដោយសារគ្រាប់មីន លោកបានទៅជួបផ្ទាល់ជាមួយសម្តេច **ប៉ាប យ៉ូហាន - ប៉ូលទី២** ដើម្បីសុំអោយព្រះអង្គបានដឹងឮនិងចូលរួមអំពាវនាវដល់ពិភពលោកទាំងមូលកុំអោយមានការផលិតគ្រាប់មីន ផ្តល់អត្ថិភាពដល់ជនរងគ្រោះដោយសារសង្គ្រាមជាពិសេសដោយសារគ្រាប់មីនអោយគេមានលទ្ធិភាពស្តារនូវពលកម្មនិងអោយមនុស្សទាំងអស់យល់ពីការលំបាកនិងទុក្ខវេទនារបស់ជនពិការ ។ ខាងក្រោមនេះជាបទសំភាសន៏របស់ព្រាបសន្តិភាពជាមួយលោក**ទន់ចាន់ណារ៉េត**ក្នុងការចូលរួមកាន់មរណៈទុក្ខនៃអគ្គពលកររបស់អាទិទេពគឺសម្តេច **ប៉ាប យ៉ូហានប៉ូលទី២** ដែលបានសុគត់កាលពីថ្ងៃទី២ មេសា ឆ្នាំ២០០៥ វេលាម៉ោង ២១និង២៧នាទីនៅបុរីវ៉ាទីកង់ ក្រុងរ៉ូម ប្រទេសអ៊ីតាលីនៃអាគារឯកជនរបស់ព្រះអង្គ

សម្តេច ប៉ាប យ៉ូហានប៉ូលទី២



លោកទុន ចាន់ណារ៉េត លោកអភិបាល គីគេ ជួប **សម្តេច ប៉ាប** សូមឱ្យលោកជួយផ្សព្វផ្សាយដល់ពិភពលោកអំពីយុទ្ធនាការលុបបំបាត់គ្រាប់មីន នៅបុរីវ៉ាទីកុង ក្រុងរ៉ូម អ៊ីតាលី ឆ្នាំ១៩៩៥

ក្នុងព្រះជន្មាយុ៨៤ ព្រះវស្សា ។

**ព.ស ក្រោយពេលលោកបានជួបសន្ទនាជាមួយព្រះអង្គ (សម្តេចប៉ាប យ៉ូហានប៉ូលទី២)ហើយតើព្រះអង្គមានចំណាប់អារម្មណ៍អ្វីខ្លះចំពោះយុទ្ធនាការលុបបំបាត់មីនរបស់លោក ?**

**រ៉េតៈ** ខ្ញុំមិនចង់និយាយថាក្រោយនោះទេ គឺថាពេលខ្ញុំបានជួបសន្ទាជាមួយលោកពេលនោះ មានមហាជនច្រើនកុះករនិងមានបណ្តាញប្រព័ន្ធផ្សព្វផ្សាយគ្រប់ទីកន្លែងលើពិភពលោកមិនថាប្រទេសមហាអំណាចរឺមិនមហាអំណាចនោះទេ ។ក្នុងថ្ងៃនោះលោកបានអំពាវនាវបីលើក ។ក្រោយពេលខ្ញុំចាកចេញពីក្រុងរ៉ូមព្រះអង្គបានប្រកាសរហូតដល់ប្រាំពីរដងក្នុងមួយថ្ងៃដើម្បីចូលរួមនូវការលុបបំបាត់គ្រាប់មីន *តទៅទំព័រទី២*




## តើខ្ញុំជាមួយនិងកូនសំរេចចិត្តទៅរកភូមិករវិញ រឺក៏ឆ្ពោះទៅប្រទេសទី ៣ ?

ចាប់តតាំងពីឆ្នាំ២០០៤ខែមេសារហូតមកដល់ថ្ងៃនេះមានជនជាតិមុងតេងញ៉ាតប្រមាណ ៧៨៨នាក់បានភៀសខ្លួនពីតំបន់ភ្នំវៀតណាមមករស់នៅព្រះរាជាណាចក្រកម្ពុជាដោយឆ្លងកាត់ព្រំដែន ខេត្តរតនៈ គីរីនិងមណ្ឌលគីរី ។ ជនជាតិភាគតិចទាំងនោះភៀសខ្លួនដោយមូល ហេតុ បញ្ហាដីធ្លីបិទសិទ្ធិសេរីភាព សាសនានិងនយោបាយ ។ ក្នុងចំណោមប្រមាណ ៧៨៨នាក់មានប្រមាណ៨០នាក់ទៅប្រទេសទីបី( សហរដ្ឋអាមេរិក) ដោយឆ្លងកាត់ការសំភាសន៏ចំនួន៦៦៨នាក់កំពុងបន្តរស់នៅក្រុងភ្នំពេញនិង៤០នាក់ផ្សេងទៀតត្រលប់ទៅវៀតណាមវិញ ។ក្រុមទីមួយដែលត្រលប់ទៅវិញបានដឹងថាបានទៅរស់នៅកន្លែងដើមវិញប៉ុន្តែក្រុមបន្ទាប់មកទៀតមិនអាចទាក់ទងបានព្រោះ UNHCR អាចជូនក្រុម តំបន់ភ្នំទាំងនេះបានត្រឹមតែព្រំដែនព្រះរាជាណាចក្រកម្ពុជា-យួនតែប៉ុណ្ណោះ ។ ថ្មីៗនេះមានជនជាតិមុងតេងញ៉ាតចំនួនបួននាក់ដែលបានកើតនៅក្រុងភ្នំពេញនិងស្ត្រីម្នាក់បានស្លាប់ដោយរោគស្ត្រី ។ រដ្ឋាភិបាលក្រុងភ្នំពេញមានជំរើសពីរសំរាប់ជនជាតិមុងតេងញ៉ាតនេះ ទីមួយបញ្ជូនទៅប្រទេសទីបី ទីពីរត្រលប់ទៅវៀតណាមវិញ ។

By TinTin

N″05_Mar_A.qxd 06/16/2006 10:26 Morning Page 2

## បណ្ដាញសាលាមេត្តាករុណាជួបជុំគ្នាផ្លាស់ប្ដូរបទពិសោធន៍និងប្ដេជ្ញា ចិត្តរួមគ្នាអភិវឌ្ឍន៍ធនធានមនុស្ស

គ្រូនិងបុគ្គលិកអប់រំសរុបចំនួន៩៥នាក់មកពីគ្រប់បណ្ដាខេត្តដែលជាបណ្ដាញសាលាមេត្តាករុណាបានចូលរួមសិក្ខាសាលាស្ដីអំពីការអប់រំនិងការអភិវឌ្ឍន៍ធនធានមនុស្សសិខាសាលានេះបានប្រព្រឹត្តទៅអស់រយៈពេល៥ថ្ងៃគឺចាប់ពីថ្ងៃច័ន្ទទី២៨ខែមីនាដល់ថ្ងៃសុក្រទី១ ខែមេសាឆ្នាំ២០០៥នាព្រះវិហារកាតូលិកក្រុងព្រះសីហនុ ។ក្នុងគោលបំណងរួមចំណែកអភិ-វឌ្ឍន៍ការអប់រំអោយកាន់តែមានគុណភាព ។ សិក្ខាកាមដែលមកចូលរួមគឺជាគ្រូមកពីតាមបណ្ដាសាលាដែលបានទទួលការឧបត្ថម្ភពីអង្គការJS មេត្តាករុណានិងបុគ្គលិកផ្នែកអប់រំ ។ ក្នុងសិក្ខាសាលានេះលោកគ្រូអ្នកគ្រូបានផ្លាស់ប្ដូរយោបល់គ្នាចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក ធ្វើតេស្តស្វែងរកចំនុចខ្វះខាតរបស់គ្រូលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យាគ្រូបង្ហាញពីគោលបំណងរបស់ខ្លួនចំពោះសិស្សនិងរួមគ្នាស្វែងរកវិធីសាស្ត្រជួយអោយកុមារទទួលបាននូវការអប់រំមួយដែលប្រកបដោយគុណភាពសំដៅជួយកុមារអោយមានចំណេះ



អ្នកគ្រូ សម្បត្តិ ប្រើរូបភាពអំពីចំនួនលេខ ៥

ដឹងខ្ពង់ខ្ពស់ក្លាយទៅជាមនុស្សល្អមានសីលធម៌មិនប្រព្រឹត្តអំពើអាក្រក់ ចេះស្រលាញ់បរិស្ថានស្រលាញ់សម្បត្តិវប្បធម៌ប្រពៃណីនិងក្លាយទៅជាអ្នកដឹកនាំល្អទៅថ្ងៃអនាគត។ ឆ្លងកាត់ការប្រជុំផ្លាស់ប្ដូរយោបល់ ស្វែងរកវិធីសាស្ត្រ និងហែលទឹកកំសាន្តអស់រយៈពេល៥ថ្ងៃ សិក្ខាសាលាបានបញ្ចប់ទៅដោយជោគជ័យ និងសប្បាយរីករាយបំផុត។ នៅថ្ងៃបញ្ចប់សិក្ខាសាលាលោកគ្រូអ្នកគ្រូបានផ្ដាច់ញ្ញាចិត្តនិងរួមគ្នាអភិវឌ្ឍន៍ធនធានមនុស្សនិងវិស័យអប់រំអោយកាន់តែមានគុណភាពល្អ។ *ដោយណុត*

## ទូន ចាន់ណារ៉េត ″ ខ្ញុំមានអារម្មណ៍ដ៏សោកសៅបំផុត...

ឈប់ផលិតមីនឈប់អោយមានសង្គ្រាមនៅទូទាំងពិភពលោក។

**ព.ស ក្រោយពេលលោកបានទទួលដំណឹងពីមរណៈភាពរបស់សម្ដេចប៉ាប តើលោកមានអារម្មណ៍យ៉ាងណាដែរ?**

**រ៉េតៈ** ជាការពិតណាស់ខ្ញុំមានអារម្មណ៍សោកស្ដាយនិងធ្លាក់ទឹកចិត្តជាខ្លាំងចំពោះមរណៈភាពរបស់ព្រះអង្គព្រោះសម្ដេចប៉ាបជាសរសរទ្រូងរបស់ព្រះសហគមន៏កាតូលិកនិងជាអ្នកកសាងសន្តិភាពសំរាប់មនុស្សទូទៅមិនថាពុទ្ធបរិស័ទ្ធ ឥស្លាមបរិស័ទ្ធឺសាសនាណាឡើយ។ សំរាប់ខ្ញុំផ្ទាល់ព្រះអង្គជាតំណាងព្រះគ្រីស្តដែលមានក្ដីស្រលាញ់អាណិតអាសូរលើកលែងទោសកសាងសន្តិភាពដោយមិនខ្លាចបូជាជីវិត។ ខ្ញុំនូវចងចាំថ្ងៃមួយពេលព្រះអង្គកំពុងធ្វើធម្មទេសនាមានឃាតករចង់ធ្វើឃាតព្រះអង្គប៉ុន្តែមិនបានសំរេចគ្រាន់តែរងរបួសតែប៉ុណ្ណោះក្រោយមកព្រះអង្គលើកលែងទោសអោយឃាតករនោះរួចទោសដោយសោមនស្សទាំងនេះសរបញ្ជាក់ថាព្រះគ្រីស្តគង់នៅជាមួយព្រះអង្គយ៉ាងជាក់ច្បាស់។

***ព.ស តើលោកមានមតិផ្ដែផ្ដាំអ្វី ខ្លះ ដល់មហាជនទូទៅ?***

**រ៉េតៈ** ក្នុងនាមខ្ញុំជាជនរងគ្រោះម្នាក់ក៏ដូចក្នុងពិភពលោកទាំងមូលសូមអំពាវនាវអោយគ្រិស្តបរិស័ទ្ធទាំងអស់ចេះកសាងសន្តិភាពមានមេត្តាករុណាធម៌កុំរើសអើងពូជសាសន៍ប្រកាន់ សច្ចធម៌និងចែករំលែកនូវអ្វី១ដែលខ្លួនទទួលបានពីព្រះវិញ្ញាណអោយដល់អស់អ្នកដែលរស់នៅជិតខាងនិងអ្នកដែលពុំទាន់ស្គាល់ព្រះជាម្ចាស់។ សូមអង្វរដល់អស់លោកដែលមានគំនិតគុំគួនឃោរឃៅចូលចិត្តធ្វើសង្គ្រាមតែងតែប្រព្រឹត្តអំពើអាក្រក់សូមអោយអ្នកទាំងនោះកែប្រែចិត្តគំនិតមកកសាងសន្តិភាពវិញដូចពាក្យរបស់សម្ដេចប៉ាបថា ″សង្គ្រាមិនអាចដោះស្រាយបញ្ហាឡើយ″។ ខ្ញុំសូមអធិដ្ឋានក្នុងការជ្រើសរើសសម្ដេចប៉ាបថ្មី សូមអោយព្រះអង្គប្រកបដោយព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។ By TinTin

## មិត វ៉ៃ ″ មិនជាការងាយស្រួលទេ ដោយប្រើជើងក្នុងការសរសេរ ″

**មិត វ៉ៃ**អាយុ២២ឆ្នាំពិការតាំងពីកំណើតហើយកំព្រាឪពុកម្ដាយតាំងពីតូចមកម្ល៉េះ។ សព្វថ្ងៃលោករៀនថ្នាក់ទី១២នៃវិទ្យាល័យហ៊ុន សែនតាខ្មៅ ខេត្តកណ្ដាល ស្នាក់នៅសាលាឡាវ៉ាឡា（Lavala ）។ ក្នុងថ្នាក់រៀនមានសិស្សពិការតែម្នាក់ឯងគត់ព្រមទាំងមានការលើកទឹកចិត្តពីមិត្តភក្តិ។ ក្នុងការសិក្សា មិត វ៉ៃ ចាប់អារម្មណ៍ទៅលើផ្នែក កុំព្យូទ័រ និងភាសាអង់គ្លេស។ នេះជាកិច្ចសម្ភាសរវាងអ្នកយកពតិមាននៃព្រឹត្តិបត្រ ព្រាបសន្តិភាព និង មិត វ៉ៃ ដែលមានខ្លឹមសារដូចខាងក្រោម។

**ព.សៈតើលោកអាចប្រាប់បានទេថាលោកពិការដោយសារមូលហេតុអ្វី?**

**វ៉ៃៈ** បាទតាមពិតទៅខ្ញុំពិការតាំងពីកំណើតមកម្ល៉េះមិនបណ្ដាលមកពីការចាក់ថ្នាំរឺដោយសារគ្រោះថ្នាក់អ្វីឡើយ។ ដៃរបស់ខ្ញុំពិការទាំងពីរគ្មានកំលាំងនិងជើងស្ដាំម្ខាងទៀតក៏មិនអាចកំរើកបានដែរតែជាសំណាងល្អខ្ញុំនៅមានជើងឆ្វេងម្ខាងគត់សំរាប់ប្រើបានក្នុងជីវិតរបស់ខ្ញុំ។

**ព.សៈ តើលោករៀនថ្នាក់ទីប៉ុន្មានហើយ? សព្វថ្ងៃនេះសិស្សក្នុងសាលាមានអារម្មណ៍យ៉ាងណាដែរចំពោះលោកដែលជាមនុស្សពិការយ៉ាងនេះ?**

**វ៉ៃៈ** សព្វថ្ងៃនេះខ្ញុំកំពុងរៀនថ្នាក់ទី១២នៃវិទ្យាល័យហ៊ុន សែនតាខ្មៅ ខេត្តកណ្ដាល។ ជាការពិតណាស់ខ្ញុំបានដឹងថាជនពិការមានការលំបាកខ្លាំងទាំងផ្លូវកាយទាំងផ្លូវចិត្តក្នុងការទំនាក់ទំនងជាមួយអ្នកដទៃពេលខ្លះមានការរើសអើងនិងមើលងាយដោយគេពុំបានយល់ពីសិទ្ធិរបស់ជនពិការ។ ចំពោះមិត្តភក្តិក្នុងសាលារៀនវិញពួកគេបានយកចិត្តទុកដាក់និងមានការអាណិតអាសូរយ៉ាងខ្លាំងចំពោះរូបខ្ញុំ។

**ព.ស តើលោកមានការលំបាកអ្វីខ្លះក្នុងការសរសេរអក្សរដោយជើង?**



យុវជន វ៉ៃ បានលើកជើងឈ្វេងរបស់គាត់ចាប់ប៊ិចដើម្បីសរសេរជាមួយនិងទឹកមុខញញឹមលើកៅអីថ្ម

**វ៉ៃៈ**បាទមិនជាការងាយស្រួលទេដោយប្រើជើងក្នុងការសរសេរ ។មុនដំបូងខ្ញុំមានការលំបាកជាខ្លាំងពីព្រោះយកជើងកាន់ប៊ិចសរសេរមិនត្រង់បន្ទាត់ចំនុចដែលរូបខ្ញុំមិនអាចបំភ្លេចបាននោះគឺខ្ញុំបានស្រកទឹកភ្នែកព្រោះតែសរសេរលេខពីរខ្មែរមិនបានតែខ្ញុំខិតខំព្យាយាមរហូតបានសំរេចឥឡូវនេះអាចសរសេរបានទាំងភាសារខ្មែរអង់គ្លេសនិងអាចគូររូបបានផងដែរ។ *តទៅទំព័រ៤*

N"05_Mar_A.qxd 06/16/2006 10:27 Morning Page 3

# រឿង ហិបកំទេចកញ្ចក់



By. Cheatta

ករណីយកិច្ចរវាងឪពុកម្តាយនិងកូនប្រែប្រួលទៅតាមអាយុជាពិសេសក្នុងវ័យចាស់។ "មនុស្សចាស់មានចរិតដូចកូនក្មេងជាលើកទីពីរ "នេះជាសំដីរបស់អ្នកនិពន្ធរឿងល្ខោនជនជាតិក្រិច ។ រឿងនិទាននេះសំដៅទៅលើមនុស្សចាស់ជរាគឺថាពេលណាយើងយកចិត្តទុកដាក់ចំពោះចាស់ជរា គឺយើងត្រូវបីបាច់ចិញ្ចឹមគាត់ ។ កាតព្វកិច្ចរបស់កូនក្នុងការគោរពប្រណិប័តន៍ឪពុកម្តាយមិនមែនចប់ត្រឹមពេលដែលគាត់ចាស់នោះទេ។ សម័យកាលមួយនោះមានតាចាស់ម្នាក់ជាបុរសពោះម៉ាយប្រពន្ធស្លាប់ចោលហើយរស់នៅតែម្នាក់ឯង។ គាត់បានប្រឹងប្រែងប្រកបរបរជាជាងកាត់ដេរចិញ្ចឹមជីវិតតាំងពីក្មេងមកប៉ុន្តែគាត់គ្មានសំណាងព្រោះគាត់នៅតែក្រគ្មានលុយមួយសេនសេសសល់តំកល់បានសោះហើយពេលនេះគាត់កាន់តែជរាមិនអាចរកស៊ីចិញ្ចឹមជីវិតដោយខ្លួនឯងបានឡើយ ។ដៃគាត់ទាំងពីរញ័រទទ្រើកមិនអាចដោតម្ជុលបានឯភ្នែកគាត់ក៏អន់លែងដេរបានត្រង់ថ្នេរតទៅទៀតដែរ។ គាត់មានកូនប្រុសបីនាក់ប៉ុន្តែពួកគេធំៗរៀងខ្លួនហើយមានប្រពន្ធកូនអស់។ ពួកគេមមាញឹកជាខ្លាំងក្នុងជីវភាពក្រុមគ្រួសាររៀងៗខ្លួន។ គេមានពេលត្រឹមតែមួយអាទិត្យម្តងឈៀងចូលមកញាំបាយល្ងាចជាមួយនឹងឪពុកប៉ុណ្ណោះ។ បន្តិចម្តងៗតាចាស់ក៏កាន់តែថយកំលាំងទៅឯកូនគាត់ទាំងបីនាក់សោតក៏កាន់តែរយាលក្នុងការមកសួរសុខទុក្ខគាត់ផងដែរ។ គាត់ពោលតែម្នាក់ឯងថាពួកគេលែងចង់នៅក្បែរអញទៀតហើយពេលនេះពីព្រោះគេខ្លាចអញដាក់អម្រែកធ្ងន់អោយគេ ។គាត់សំរាន្តមិនលក់ពេញមួយយប់ព្រួយបារម្ភអំពីខ្លួនឯងដែលថ្ងៃមុខមិនដឹងទៅជាយ៉ាងណា ។ នៅទីបំផុតគាត់បាននឹកឃើញផែនការមួយ ។ ព្រឹកឡើងគាត់ក៏ធ្វើដំណើរទៅកាន់មិត្តគាត់ម្នាក់ដែលជាជាងឈើអោយជួយធ្វើហិបឈើធំមួយអោយគាត់ ។ បន្ទាប់មកគាត់ ទៅរកមិត្តម្នាក់ទៀតដែលជាជាងធ្វើសោរសុំបានសោរចាស់មួយ ។ ចុងក្រោយបង្អស់គាត់ទៅរកមិត្តម្នាក់ទៀតដែលជាជាងកាត់កញ្ចក់ហើយសុំកំទេចកញ្ចក់ចាស់ៗគ្រប់ធុនដែលមិត្តគាត់មាន ។ស្រេចបាច់ហើយតាចាស់ក៏ដឹកហិបឈើមកផ្ទះ។ គាត់ចាក់កំទេចកញ្ចក់ក្នុងហិបឈើឡើងពេញព្រៀបហើយចាក់សោរយ៉ាងជាប់រួចក៏រុញចូលទៅទុកនៅក្រោមតុក្នុងផ្ទះបាយ។ ថ្ងៃមួយកូនៗរបស់គាត់បានមកទទួលទានអាហារពេលល្ងាចជាមួយគាត់។ ពួកគេយកជើងធាក់ហិបឈើរួចសួរថាៈ "ស្អីគេនៅក្នុងហិបនេះ? " រួចហើយគេក៏ឈ្ងោកមេលទៅក្រោមតុបាយ ។ " គ្មានស្អីទេ " តាចាស់ឆ្លើយតបទៅកូនគាត់វិញ "វាមានតែរបស់របរបន្តិចបន្តួចដែលពុកបានសន្សំសន្សំទុកជាយូរមកហើយ ។កូនៗគាត់សង្ស័យក៏យកកែងដៃរុញហិបថ្នមៗចង់ដឹងលមើលហើយគេទទួលអារម្មណ៍ថាហិបធ្ងន់ណាស់ ។ ពួកគេយកជើងទាត់ហិបឮស្នូរវត្ថុក្នុងហិបលាន់សូររ៉ូងរ៉ាងយ៉ាងរណ្តំ។ ពួកគេខ្សឹបខ្សៀវគ្នាថា : មុខជាសុទ្ធតែមាសប្រាក់ដែលគាត់ខំសន្សំទុកជាច្រើនឆ្នាំមកហើយជាមិនខាន ។ពួកគេគិតគ្នាថាត្រូវតែចាត់គ្នាយាមហិបមាសប្រាក់នេះ។ ដូចនេះពួកគេក៏ដាក់វេនគ្នារស់នៅជាមួយតាចាស់ហើយថែរក្សាគាត់ផងដែរ ។ នៅអាទិត្យទីមួយ កូនពៅបានរើមកនៅជាមួយឪពុកមើលថែគាត់និងដាំស្លជូនគាត់ពិសារ។ អាទិត្យទីពីរកូនកណ្តាលក៏មកនៅថែឪពុកជំនួសប្អូនពៅ។ អាទិត្យបន្ទាប់មកទៀតដល់វេនកូនច្បងជាអ្នកមើលថែឪពុក។ ហើយពួកគេក៏បណ្តាក់វេនគ្នាមើលថែឪពុករហូតមក។ ចំណេរក្រោយមកតាចាស់ក៏ធ្លាក់ខ្លួនឈឺហើយអនិច្ចកម្មទៅ។ កូនគាត់ទាំងបីនាក់នាំគ្នាចាត់ចែងរៀបចំទុកដាក់សាកសពឪពុកយ៉ាងអធិកអធម្មជាទីបំផុតព្រោះពួកគេដឹងថាមានមាសប្រាក់ជាច្រើនកំពុងរង់ចាំពួកគេនៅក្រោមតុក្នុងផ្ទះបាយដែលគេអាចទូទាត់ចំណាយពិធីបុណ្យសពនេះអស់ត្រឹមតែមួយភាគតូចប៉ុណ្ណោះ។ ពេលបុណ្យសពចប់រួចរាល់ហើយពួកគេស្ទុះស្ទាទៅផ្ទះវិញរុករកកូនសោហិបឃើញហើយក៏ចាក់បើកហិបឡើង។ វាជាការពិតជាក់ស្តែងណាស់ដែលថាពួកគេបានឃើញហិបពេញសុទ្ធតែកំទេចកញ្ចក់។ "នេះបានចំជាល្បិចកលយ៉ាងស្មោកគ្រោកមែន" កូនច្បងស្រែកជំទាលឡើង " "គាត់ចេះប្រើល្បិចយ៉ាងសាហាវជាមួយកូនគាត់ទៅកើត ។ប៉ុន្តែតើនៅមានវិធីអ្វីផ្សេងដែលគាត់អាចប្រើបានទៅមែនទេ? កូនកណ្តាលសួរតបទៅបងវិញយ៉ាងក្រៀមក្រំ " យើងត្រូវតែស្មោះត្រង់ចំពោះខ្លួនឯង ។ គឺថាបើមិនដើម្បីហិបឈើនេះទេ នោះយើងមុខជាមិនវិលវល់ នឹងគាត់ រហូត ដល់គាត់ស្លាប់ឡើយ ។ "ខ្ញុំសែនអាម៉ាសចំពោះខ្លួនឯង" កូនពៅយំខ្សឹកខ្សួលពួកយើងបានបង្ខំឪពុកយើងអោយធ្លាក់ខ្លួនជាមនុស្សបោកប្រាស ពីព្រោះតែយើងមិនបានគោរពប្រណិប័តន៍តាមពាក្យប្រៀនប្រដៅរបស់គាត់ដែលបានណែនាំយើងកាលពីយើងនៅតូចៗ។"ប៉ុន្តែកូនច្បងដែលនៅមិនអស់ចិត្តក៏ផ្សៀងហិបចាក់កំទេចកញ្ចក់ចេញលើក្តារទាល់តែអស់ ព្រោះខ្លាចក្រែងមានមាសប្រាក់បង្កប់ទុកលាយឡំក្នុងកំទេចកញ្ចក់ទាំងនេះ ។ ទីបំផុតពួកគេនាំគ្នាឈរទ្រឹងស្ងៀមសំលឹងមើលទៅបាតហិបដែលមានអក្សរមួយឃ្លាសរសេរទុកថា : " ចូរគោរពប្រណិប័តន៍ឪពុកម្តាយរបស់អ្នក" ។

*រឿងនិទាននេះស្តីពីករណីយកិច្ចរបស់បុត្រធីតាគឺត្រូវគោរពប្រណិប័តឪពុកម្តាយរហូតទាល់តែគាត់ស្លាប់ ។ បកប្រែ និងកែសំរួល សុខអេង*

### កំណាព្យ " បទពាក្យប្រាំពី " ត

ម្តាយផ្ទមរូបកូននៅក្នុងផ្ទៃ អោយសុខភាពថ្លៃបានមុតមាំ
រក្សារូបកូនដោយខិតខំ ហូបចំណីទំមានជីវជាតិ ។
ពេលម្តាយពរពោះប្រាំបីខែ ផ្ទៃម្តាយចេះតែមានស៊ិកសៀត
ដោយកម្លាំងកូនរើថែមទៀត ម្តាយឈឺស៊ិកសៀតពេញទាំងផ្ទៃ ។
កូនអើយម្តាយផ្ទមកូនខ្លាំងណាស់ ទោះកូនបំរះយ៉ាងម្តេចក្តី
ពេលដែលម្តាយឈានដើររាល់ថ្ងៃ ខ្លាចតែបុត្រថ្លៃនាងរង្គើ ។
ការងារទាំងឡាយម្តាយរំលែក ទុកអោយឪឯងគាត់អ្នកធ្វើ
ព្រោះអីជីដូនកូនគាត់ស្នើ មិនអោយម៉ែធ្វើត្រូវផ្ទមខ្លួន ។
តើកូនដឹងទេណាអ្នកថ្លៃ រាល់ពេលយប់ថ្ងៃមុនដេកពួន
ម្តាយស្ទាបអង្អែលពៅតូចស្ងួន ដែលកូនអ្នកពួនក្នុងផ្ទៃម្តាយ ។
ម្តាយទឹកបួងសួងពេលកូនកើត អោយកូនល្អឆើតស្រស់ឆោមឆាយ
អវៈយវៈនិងរូបកាយ កូនរបស់ម្តាយល្អសោភា ។
មិនថាកូនកើតប្រុសឬស្រី ម្តាយស្រឡាញ់ថ្លៃកូនដូចគ្នា
ទឹកចិត្តរបស់ម្តាយស្នេហ៍ពុំងា ទោះត្រូវវេទនាយ៉ាងណាក្តី ។
ផ្ទៃម្តាយគំរប់ប្រាំបួនខែ ថ្ងៃដែលរូបម៉ែចាំចរណៃ
ឪកូនត្រៀមធ្យូងអុសឈើព្រៃ សំរាប់ដល់ថ្ងៃឆ្លងទន្លេ ។
ប្រាំបួនខែដប់ថ្ងៃម្តាយឈឺផ្ទៃ រូបម្តាយស្ទើរក្ស័យហើយមាសមេ
ថ្ងៃនេះជាថ្ងៃឆ្លងទន្លេ ម្តាយឈឺរិតទ្វេមួយជាដប់ ។
កូនអើយម្តាយឈឺខ្លាំងណាស់កូន តែរូបម្តាយស៊ូនខំខាំមាត់
ខំប្រឹងអោយកូនឆាប់ប្រសូត ដើម្បីអោយផុតពីផ្ទៃម្តាយ ។
ពាក្យចាស់លោកថាឆ្លងទន្លេ ពិតមិនខុសទេកូនឆោមឆាយ
ទន្លេម្តាយឆ្លងវែងហើយឆ្ងាយ ម្តាយហែលគាស់កាយទម្រាំផុត ។
ទន្លេធំណាស់ស្វះស្វែងខំ ប្រមូលអារម្មណ៍ខំអត់ធ្មត់
ដង្ហើមផុតៗស្ទើររលត់ ដៃជើងស្រយុតស្រយង់ប្រាណ ។
ពេលឮសំលេងកូនស្រែកយំ ម្តាយផុតទុក្ខធំទាំងប៉ុន្មាន
ទ្រូងក៏លែងភ័យស្តីស្រាកស្រាន ត្បិតកូនកល្យាណបានកើតហើយ ។
ម្តាយបីថ្នាក់ថ្នមថើបបន្ទែង អោយបុត្រតូចក្មេងបានធូរស្បើយ
ម្តាយលើកកូនថ្នមកុំភ័យឡើយ បុត្រមាសម្តាយអើយកូនគេងទៅ ។
កូនយំម្តាយលួងអោយកូនស្ងៀម ទឹកដោះជាឈាមបៀមបំបៅ
ខ្លាចកូនយំយូរកើតគ្រុនក្តៅ ម្តាយព្រួយខ្លាចពៅមានជំងឺ ។
បើរូបកូនជា ម្តាយក៏ជា បើពុំងាឈឺ ម្តាយក៏ឈឺ
ទ្រាំអត់ងងុយអង្គុយទល់ភ្លឺ ម្តាយសុខចិត្តឈឺអោយកូនជា ។
ថៃទាំបីបាច់រក្សាកូន មិនអោយមាសស្ងួនកូនរងា
ស្រមោចតូចមួយមិនអោយវារ លើខ្លួនបុត្រាទេណាថ្លៃ ។

*កំណាព្យដកស្រង់ពីសៀវភៅ អនិច្ចាអ្នកស្រែ និពន្ធដោយ អ្នកស្រី ខុង ណារី*

### សាប៊ូទាំង៣ប្រភេទមានលក្ខណៈពិសេស




**សាប៊ូព្យាបាលរមាស់**

១-លាងកមរមាស់ដោយទឹកឧណ្ហ៍ៗជាមួយសាប៊ូ
២-ជ្រលក់ថ្នាំក្នុងទឹកដុសកន្លែងមានរមាស់ទុកអោយសស្ងួត
៣-ដុសព្រឹកម្តង ល្ងាចម្តងរហូតជារមាស់។




**សាប៊ូចៃ**

១-កក់សាប៊ូចៃលើក្បាល
២-ទុកដប់នាទីកក់ចេញ
៣-ជូតអោយស្ងួតសិតដោយស្និត
៤-៧ថ្ងៃកក់ម្តងទៀតបំបាត់មូស។




**បំបាត់មូស**

១- បំបាត់មូសប្រើរាល់ថ្ងៃមុនថ្ងៃលិច
២-ជ្រលក់ក្នុងទឹកបន្តិច
៣-ដុសកន្លែងល្បែងទទេញអោយសព្វ
៤-ទុកក្នុងស្រោមអោយជិត

N"05_Mar_A.qxd 06/16/2006 10:28 Morning Page 4

# " កុំភ្លេចទី "



រូបថតរបស់សម្តេចប៉ាប យ៉ូហាន ប៉ូលទី២




សម្តេចព្រះ បរមនាថ នរោត្តម សីហមុនី គោរពវិញ្ញាណក្ខន្ធសម្តេចប៉ាប ដោយមានព្រះសង្ឃទាំងពីគណៈនិងលោកអភិបាលទាំងបួនអង្គអម

បន្ទាប់ពីសម្តេចសង្ឃកាតូលិកដ៏ល្បីល្បាញគឺសម្តេច**ប៉ាប យ៉ូហាន ប៉ូលទី២** បានទទួលមរណៈនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៥ ធ្វើអោយគ្រីស្តបរិស័ទនិងអ្នកដែលគោរពស្រលាញ់នូវអំពើរល្អរបស់ព្រះអង្គទូទាំងពិភពលោកមានការភ្ញាក់ផ្អើលនិងសោកសៅយ៉ាងខ្លាំង ។ដោយឡែកនៅប្រទេសកម្ពុជានៅថ្ងៃទី៧ ខែមេសាឆ្នាំ២០០៥ មានអភិបូជាដើម្បីប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធដ៏ធំមួយដល់ សម្តេចប៉ាបយ៉ូហានប៉ូលទី២ នៅព្រះវិហារកាតូលិកផ្សារតូច ក្រុងភ្នំពេញ ។ ក្នុងអភិបូជាដ៏ធំនេះមានព្រះរាជវត្តមានដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះបាទ បរមនាថ នរោត្តម សីហមុនី សម្តេចសង្ឃតំណាងអោយព្រះពុទ្ធសាសនាទាំងពីរគណៈលោកអភិបាលទាំង៤ លោកបូជាចារ្យព្រមទាំងគ្រីស្តបរិស័ទប្រមាណជាងមួយពាន់នាក់មកពីភូមិភាគទាំងបីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះក៏មានបុគ្គលិកអង្គការ JS ប្រមាណ៨០នាក់ផងដែរចូលរួមពិធីគោរពព្រះវិញ្ញាណក្ខន្ធរបស់សម្តេចប៉ាប ។ ក្នុងអភិបូជានេះលោកអភិបាល **អេមីល** អានអានវត្តិរូបនិងសកម្មភាពរបស់ព្រះអង្គក្នុងប្រទេសមួយចំនួនដែលព្រះអង្គបានទៅពេលនេះដែរមានចំរៀងទំនុកតំកើងនិងព្រះបន្ទូលរបស់ព្រះជាម្ចាស់ផងដែរ ។ **ព្រះករុណាព្រះបាទ បរមនាថនរោត្តមសីហមុនី**សំដែងទឹកមុខដ៏ក្រៀមក្រំបំផុតហើយព្រះអង្គទ្រង់ក៏បានចារនៅលើសៀវភៅចំណាមរណៈទុក្ខថាព្រះអង្គសូមសំដែងនូវសេចក្តីក្រៀមក្រំយ៉ាងខ្លាំងចំពោះអនិច្ចធម្ម របស់សម្តេចប៉ាប យ៉ូហាន ប៉ូលទី២ ហើយព្រះអង្គបានថ្វាយសារនិងផ្កាគោរពវិញ្ញាណក្ខន្ធជូនចំពោះសម្តេច ប៉ាប។ ចុងបញ្ចប់អភិបូជាលោកអភិបាលបូជាចារ្យនិងគ្រីស្តបរិស័ទ្ធបានអរព្រះគុណ **ព្រះករុណាព្រះបាទ បរមនាថនរោត្តមសីហមុនី** ដែលបានចូលរួមរំលែក មរណៈទុក្ខនេះ។ ដោយ ណុត-TinTin

*នេះជាគំនូនិងអក្សរដោយប្រើជើងជំនួសដៃ*

## មិត វ៉ៃ




កាលពីមុនខ្ញុំមានក្រុមភ្លេងរបស់ខ្ញុំតែឥឡូវនេះបែកគ្នាអស់ហើយ ។ខ្ញុំអាចលេងកីឡាបានខ្លះដូចជាប៉ូលដ៏វវ៉ៃកអុកពេលទំនេរពីការរៀនសូត្រ ។

**ព.ស តើទៅថ្ងៃអនាគតលោកមានបំណងចង់ធ្វើអ្វីដែរ?**

**វ៉ៃ:** សំរាប់ខ្ញុំ ខ្ញុំពុំដឹងច្បាស់លាស់ទេតើខ្ញុំអាចប្រលងបាក់ឌុបជាប់រឺយ៉ាងណានោះទេព្រោះថាខ្ញុំត្រូវការរទេះមានអ្នកផ្សេងម្នាក់ទៀតជួយរុញ។ ខ្ញុំទៅបានដោយខ្លួនឯងបានប៉ុន្តែយឺតៗទោះបីមានលក្ខណះបែបនេះក៏ខ្ញុំមានគោលបំណងចង់ក្លាយទៅជាគ្រូភាសារ អង់គ្លេសនិងគ្រូកុំព្យូទ័រ។

**ព.សតើលោកមានសំនូមពររឺពាក្យពេចន៏អ្វីខ្លះសំរាប់មនុស្សទូទៅ?**

**វ៉ៃ:** អ្វីដែលសំខាន់បំផុតនោះគឺសូមអោយជនពិការទាំងអស់មានក្តីសង្ឃឹមក្នុងការរស់នៅខិតខំទាក់ទងតាមអង្គការរឺមណ្ឌលទាំងឡាយណាដែលជួយជនពិការនិងខិតគ្រប់បែបយ៉ាងប្រសិនបើមានឧកាសរៀនសូត្ររឺជំនាញអ្វីសូមខំព្យាយាមអោយបានសំរេច ។សូមអោយបងប្អូនទាំងអស់ជាពិសេសនៅព្រះរាជាណាចក្រកម្ពុជាជួយលើកស្ទួយជនពិការគ្រប់ប្រភេទព្រោះថាសកលលោកទាំងមូលប្រារព្ធទិវាសិទ្ធិជនពិការពាធ្នូរៀងរាល់ឆ្នាំ ។សុំអោយមនុស្សទូទៅកុំអោយមានការរើសអើងមើលងាយមើលថាកចំពោះជនពិការព្រោះយើងទាំងអស់គ្នាជាមនុស្សដូចគ្នាមាន ជីវិតដូចគ្នា ។

*ដោយ ជាតា- TinTin*